# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៤៤៣ សសរ.កសក

## សេចក្ដីសម្រេច
## ស្ដីពី
## ការប្រគល់ភារកិច្ចជូនទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្ដីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយដ្ឋានកសិកម្ម និងការកែសម្រួលអគ្គ-នាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញសេចក្ដីសម្រេចលេខ៣៦២ សសរ.កសក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីរបៀបរបបការងារនិងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខៈ (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខៈ (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## សម្រេច

**ប្រការ ១** : ត្រូវបានប្រគល់ភារកិច្ចជូនទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដូចខាងក្រោម៖

១: ឯកឧត្តម **តេង ឡៅ** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ពាក់ព័ន្ធនឹងគណៈកម្មការជំរុញការនាំចេញកសិផល
- នាទីផ្សព្វផ្សាយកសិកម្ម វេទិកាស្វែងយល់ពីកសិកម្ម និងទស្សនាវដ្តីកសិកម្ម
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

២: ឯកឧត្តម **ណើ លន់** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងការងារអគ្គាធិការដ្ឋាន និងការងារសវនកម្មផ្ទៃក្នុង
- ការងារតាំងពិព័រណ៍ជាតិ និងពិព័រណ៍អន្តរជាតិ
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៣: ឯកឧត្តម **សៀក ឡេង** ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ និងគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្ទៃកងឯកជន
- ពាក់ព័ន្ធនឹងវិស័យជលផល
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៤: ឯកឧត្តម **ចាន់ ហេង** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងគម្រោងកម្មវិធីឡជីវៈឧស្ម័នជាតិ (NBP)
- ពាក់ព័ន្ធនឹងវិស័យផលិតកម្មនិងបសុព្យាបាល និងការងារនាយកដ្ឋានកិច្ចការរដ្ឋបាល
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៥: ឯកឧត្តម **សៅ សំអូរ** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- គណៈកម្មាធិការជាតិអភិនិយោគរបស់រដ្ឋលើសហគ្រាសចម្ការកៅស៊ូ ក្រុមហ៊ុនសម្ភារកសិកម្ម និងក្រុមហ៊ុនជលផល
- ពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍន៍ប្រជាជន និងសង្គមកិច្ចជាមួយក្រសួង ស្ថាប័នផ្សេងៗ
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៦: ឯកឧត្តម **ថៃ ឫទ្ធី** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (វិមជ្ឈការ និងវិសហមជ្ឈការ)
- ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទក្រសួង
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៧: ឯកឧត្តម **ម៉ែន ឌុធ** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងការអនុវត្តផែនការសកម្មភាពស្តីពីយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចបួនប្រទេស កម្ពុជា ឡាវ វៀតណាម និងថៃ
- ពាក់ព័ន្ធនឹងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ(CARD) គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា(CNMC) គណៈកម្មការទន្លេមេគង្គ(MRC) និងអង្គការពាណិជ្ជកម្មពិភពលោក(WH
- ក្នុងក្របខ័ណ្ឌក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក(TWGA-W)
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៨: លោកជំទាវ **ឆ្វែង ហេង** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងការងាររណសិរ្ស សាមគ្គី-អភិវឌ្ឍន៍មាតុភូមិកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ
- ពាក់ព័ន្ធការងារយេនឌ័រ និងការងារអគ្គនាយកដ្ឋានកសិកម្ម
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

៩: លោកជំទាវ **ឆ្វី ស៊ីវ៉ោ** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ពាក់ព័ន្ធនឹងក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ពាក់ព័ន្ធនឹងគណៈកម្មាធិការជាតិ ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីរាតយកដីធ្វើកម្មសិទ្ធិ និងការងារអនុវត្តសន្ធិសញ្ញាប្រយុទ្ធប្រឆាំងនឹងភាពរហោស្ថានរបស់អង្គការសហប្រជាជាតិ(UNCCD)
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

១០: ឯកឧត្តម **អ៊ុក ស៊ីផាន** ទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបន្ទុកលើកិច្ចការ ៖
- ពាក់ព័ន្ធនឹងការងារកសាងលិខិតបទដ្ឋានក្រសួង
- ចូលរួមប្រជុំ ពិភាក្សា ផ្តល់យោបល់លើការងារផ្សេងៗទៀតតាមការចាំបាច់ដែលក្រសួងប្រគល់ជូន។

**ប្រការ ២** : រាល់ការចូលរួមក្នុងកិច្ចប្រជុំ ឬក្នុងវេទិកានានា ត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ។

**ប្រការ ៣** : ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ រាជធានី-ខេត្ត និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨ កើត ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ១០ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ កាលប្បវត្តិ